**វាចាអ្នកនិពន្ធ**

សួស្តីប្រិយមិត្តទាំងអស់របស់ សុភាប្រុស!!!

នៅក្រោយសំណុំរឿង គម្រោងការសម្ងាត់២០៣៥ គូស្នេហ៍កញ្ញាសន្សានិងទេវបុត្រLorenzoបន្សល់ស្លាកស្នាមស្អិតស្អែរក្នុងបេះដូងនៅឡើយពិតមែនទេ បានជាដៃអ្នកចាប់កាន់សៀវភៅនេះឡើង?

សៀវភៅថ្មីនេះខ្ញុំបានឱ្យចំណងជើងថា **ទោះស្នេហ៍ឆ្ងាយហួសជើងមេឃ** ដែលជាកាលៈទេសៈតស៊ូរបស់អ្នកទាំងទ្វេក្នុងការស្វះស្វែងរកស្នេហ៍ពិតរបស់ខ្លួនត្រឡប់មកក្នុងជីវិតវិញ។

ខ្ញុំបានចាប់ផ្តើមជាមួយនឹងតួប្រុស ដែលលែងស្គាល់ខ្លួនឯង នៅបន្ទាប់ពីគ្រោះថ្នាក់ចរាចរណ៍មួយកើតឡើងចំពោះគេ ចំណែកកូននាគសន្សា បានត្រូវគ្រួសារនាងរកឃើញហើយចូលមកទៅរស់នៅក្នុងក្រុងភ្នំពេញវិញចោល "ផ្ទះអនាគត" ជាទីកំណើតស្នេហ៍។

រយៈពេល៥ឆ្នាំក្នុងទ្រនំអភិជន នាងបានក្លាយជាកូនស្រីច្បង ដែលទើបរកឃើញរបស់អគ្គនាយកស្ថាប័នហិរញ្ញវត្ថុ OCហើយក៏ជាបងស្រីភ្លោះរបស់ពិនណា។

សន្សាពីអ្នកគ្រូជនបទ បានក្លាយមកជានារីដែលរម្យទម លែងមាត់ប៉ប្លែចប៉ប្លូចព្រោះតែអម្រែកទទួលខុសត្រូវការងារជំនួសឪពុកនិង ទំហំវិបត្តិបាត់សង្សារសំណព្វ។

ពេលបង្ហាញខ្លួនមកវិញ ទេវបុត្រ Lorenzoមិនបានស្គាល់នាង ថាជាអ្នកណាទៀតឡើយ។

មិនតែប៉ុណ្ណោះគេបានវិលមកវិញជាមួយតួនាទីជាគូដណ្តឹងនៃប្អូនស្រី ។

ស្រីណាមិនឈឺ?

......

ភាគនិទានរបស់យើង ចាប់ផ្តើមហើយ គឺចាប់ផ្តើមជាមួយការណាត់ជួបលើកទី១៥របស់នាងព្រោះលើកមុនៗគេមិនដែលព្រមចេញមកជួបស្រីតូចម្នាក់នេះឡើយ»

.....តោះទៅ! ទៅជាមួយគ្នា ទៅជាមួយអ្នកនិពន្ធធ្វើសាក្សីឱ្យសន្សារបស់យើង!



**ស្រីម្នាក់ដែលគេបំភ្លេចចោល**

គ្រាមួយ នៅចំកណ្តាលនៃជីវិតដ៏សាមញ្ញរបស់មនុស្សស្រីម្នាក់ ពេលដែលបេះដូងនាងកំពុង សស្អាត ទៅដោយភាពរួសរាយ ស្រស់បំព្រង និងសេចក្តីសង្ឃឹម ស្រាប់តែ ព្រហ្មលិខិតបានប្រគល់មកឱ្យនូវ ពិសោធន៍ស្នេហ៍មួយ ដែលស្តាប់ទៅ ហាក់បីដូចជា រឿងនិទាន ដ៏សែនរំភើប។

«អ្នកណាគេ Lorenzo?ឈ្មោះប្លែកម៉េះ ? ហើយឡើងពិបាកអាន! ឡើងពិបាកហៅ? ជនជាតិ? ខ្មែរ ឬ បារាំង? អត់ខ្វល់! ឱ្យតែគេប្រាកដជាព្រមជួយមែន ខ្ញុំខ្លាចអីទៅជួបគេ ស្មានថាខ្ញុំមិនចេះនិយាយ អ្នកស្ម័គ្រចិត្តសាសន៍គេអី ខ្ញុំធ្លាប់ស្គាល់ហើយទាំងអស់ ខ្ញុំបង្រៀនជនជាតិភាគតិចក្នុងព្រៃឱ្យលេង Facebookបង្កើតpage កុលសម្ព័ន្ធទៀត បងឯងជឿអត់ថ្ងៃណាមួយ ខ្ញុំរកលុយបាន ខ្ញុំនឹង Boost page ជនជាតិក្នុងព្រៃ ឱ្យគេស្គាល់ពេញប្រទេសម្តង!»

នាងចាប់ផ្តើមទន្ទេញឈ្មោះរបស់គេទោះជាវាពិបាកហៅ ហើយក្រោយមកនាងមិនចាំបាច់ប្រកបវាទេ ព្រោះនាងចងចាំក្នុងបេះដូង ទាំងឈ្មោះគេ ទាំងស្នាមញញឹម សំឡេងកំប្លុកៗរបស់គេ ឫកពាឆ្មើងកន្ទ្រើងគួរឲ្យស្រលាញ់របស់គេហើយនិង.....ចិត្តដ៏ស្មោះរបស់គេ។

ចុងក្រោយ គេបានទៅបាត់ ហើយគេមិនដែលមានដំណឹងអ្វីមកសូម្បីម្តង។

គេដូចជាមនុស្សប្រុសជាច្រើនដែលប្រលោមលោកបានសរសេរទុក ពីចិត្តព្រានរបស់គេ ពេលឃ្លាតឆ្ងាយក៏ណាយចិត្ត?

អត់ទេ!

បងមិនបានបំភ្លេចកូននាគតូចម្នាក់នេះទេមែនទេ?

អ្នកណាម្នាក់ អ្វីមួយ សម្ពាធអ្វីមិនដឹងដែលបង្ខំបងឱ្យធ្វើអញ្ចឹង។

ប៉ុន្តែ៥ឆ្នាំហើយ Lorenzoខ្ញុំរស់ដោយលំបាកយ៉ាងណាដែលរាល់ដង្ហើមចេញចូល នឹកឃើញទន្ទេញតែឈ្មោះរបស់បង?

ស្នូរគោះទ្វារតុៗស្រាលៗ ធ្វើឲ្យនាងចាកចេញពីភាពលន្លង់លន្លោចហើយងើបមុខ។ ជាមួយកែវភ្នែកក្រៀមស្រពោន នាងមិនទាន់និយាយអ្វីតែអ្នកគោះបានចូលមកដល់។

គេអោនលំទោនមុនពេលវាចាៈ

«លោកថា អនុញ្ញាតឲ្យនាងចូលទៅបាន!»

មាណវីក្រោកឃើតៗ តែកែវភ្នែកនាងព្រិចរហ័សព្រោះសេចក្តីរំភើប។

«អរគុណបង!»

នាងឆ្លើយដោយសារលោក់ទុកសូរសព្ទញាប់ញ័រ។

អ្នកណាដែលថា អាចទប់សកម្មភាពខាងក្រៅ មិនឲ្យបង្ហាញថាខ្លួនកំពុងរងឥទ្ធិពលពីអារម្មណ៍រញ៉េរញ៉ៃទាំងប៉ុន្មាននេះបាន អារម្មណ៍តក្កមា អារម្មណ៍ភ័យព្រួយ អារម្មណ៍សប្បាយអរ ដែលវាយសន្ធប់ក្នុងពេលតែមួយ។

មិនតិចជាង១០ដងហើយដែលនាងមកអង្គុយចាំជួបគេ ហើយជាទៀងទាត់ នាងត្រូវបានបដិសេធ។

សេចក្តីស្រលាញ់និងភាពមានៈ នៅមិនស្មើចិត្តស្មោះរបស់នាងចំពោះគេ។នាងនៅតែត្រឡប់វិញ ហើយថ្ងៃនេះ នាងបានសម្រេចក្នុងការឃើញមុខគេ បន្ទាប់ពីលែងបានសូម្បីតែឮសំឡេងគេ ជាង ១៥០០ថ្ងៃ។

«៥ឆ្នាំហើយLorenzo!»

នារីទន្ទេញពាក្យនេះជាសម្ងាត់ក្នុងបេះដូង ហើយទឹកភ្នែកចាប់ផ្តើមរលើងរលោងស្រោបកែវភ្នែកទាំងសង។

ស្នូរជើងអ្នកនាំផ្លូវមួយជំហានៗដូចជា សន្ទឹកទូងស្គរកក្រើកបេះដូងនាង ។

អ្នកនាំផ្លូវនិយាយរំឭកតិចៗ៖

«អ្នកនាងចង់មានប្រសាសន៍អ្វី កុំវែងឆ្ងាយយូរ!អ្នកនាងឆាប់និយាយជាមួយគាត់ ព្រោះគាត់មិនអាចជជែកបានយូរទេ!»

បេះដូងស្រីក្តុកក្តាក់ជាមួយទុក្ខកង្វល់ និងចិត្តអាណិតខ្លោចផ្សា។

សុខទុក្ខរបស់គេ តែងតែធំវិលេងពីលើសុភមង្គលរបស់នាង បានជានាងលែងគិតអ្វី ក្រៅតែពីគិតឃើញអំពីសុខទុក្ខរបស់គេ។

នាងសួរលឿនជាងសំនួរក្នុងបេះដូងទៅទៀត៖

«បង! គាត់ម៉េចហើយ!សុខភាពគាត់?»

អ្នកនាំផ្លូវទំនងជាមិនចង់និយាយអ្វីទាំងអស់។

គាត់ជាបុរសម្នាក់ មានទឹកមុខស្មើហាក់មានអាការៈ ប្រុងប្រយ័ត្នខ្ពស់ជានិច្ចគ្រប់កាយវិការដែលសម្ដែងចេញ។  ប្រការដែលគាត់ មិនព្រមផ្តល់ចម្លើយអ្វីជុំវិញសំនួរនេះ ធ្វើឲ្យដង្ហើមស្រី កាន់តែ តឹងបង្អួស។ នាងឈ្ងោកមុខ ដើរទៅតាមពីក្រោយបុរសនេះត្រុកៗ។

ជិតដល់ទ្វារ អ្នកនាំផ្លូវក៏បង្អង់ឈប់ហើយចាប់ផ្តើមងាកមកវាចាបញ្ជាក់នឹងនាងខ្សឹបៗ៖

«អ្នកនាង ចូលទៅចុះ! ហើយកុំភ្លេច ឆាប់និយាយ នូវរឿងសំខាន់ៗ កុំពង្វាងយូរ! អូនៃ  អ្នកនាង មានពេល តែ១៥នាទីទេ!»

ស្រីស្អាតដកដង្ហើមវែង ពេលក្រឡេកឃើញដៃ អ្នកនាំផ្លូវ លូកប៉ះទ្វារ ដែលពាក់កណ្តាលជា កញ្ចក់ខ្មៅអាច់កំបាំង អមការពារ ដោយស៊ុមឈើរលោងរលើប។ នាងនិយាយខ្សឹបៗ ដាក់គូសន្ទនា។

«ប៉ុណ្ណឹងគ្រប់ហើយ!»

គេនោះងក់ក្បាលផ្ទក់ៗនឹងចរិតនឹងនរបស់នាងដែលបញ្ចេញមក ។ ទោះមិនទាន់រុញទ្វារចូល ដៃគេបែរជាគោះប៉ូកៗឱ្យសញ្ញាសិន ។

ស្រស់ស្រីឆ្លៀតពេលពោលបន្ថែមតិចៗ៖

«ហើយ ខ្ញុំឈ្មោះសន្យា!   ក្រោយៗ ឈប់ហៅខ្ញុំអ្នកនាងៗ ទៅ!»

**ម្ចាស់បេះដូង**

បរិវេណខាងក្នុងបន្ទប់ ហាក់ជាពិភពមួយផ្សេងដែលពុំគួរឲ្យមនុស្សគ្រប់គ្នាចង់រស់នៅទាល់តែសោះ។ គ្រប់យ៉ាង ងងឹតស្រអាប់ពឹងលើតែកូនអំពូលតូចមួយគត់ ធ្វើម៉េចអាចបង្ហាញអ្វីៗឲ្យច្បាស់ស្រលះ បាន?

ជញ្ជាំងចំពីមុខ បិទដោយផ្ទាំងក្រដាស ពណ៌តូចៗជាច្រើន ហើយផ្ទាំងនីមួយៗ មានសរសេរ ពាក្យពេចន៍ ក្រវេមក្រវាម ជាភាសាអង់គ្លេសនៅលើនោះតែពិបាកបន្តិច ក្នុងការមើលឲ្យឃើញច្បាស់អត្ថន័យ។

នាងវិះនឹងមិនចាប់អារម្មណ៍ថា គេអង្គុយបែរខ្នងនៅកន្លែងនោះ។

គេប្រហែលកំពុងផ្តោតអារម្មណ៍ទៅលើសន្លឹកសំណេរជាច្រើនសន្លឹក រហូតដល់ថ្នាក់មិនរវល់ថាមានដង្ហើមមនុស្សទីពីរចូលមកចែករំលែកអុកស៊ីសែនដ៏តឹងតែងនេះជាមួយគ្នា។

«ហេតុអីមករស់នៅកន្លែងអញ្ចឹង?»

នាងភ្លាត់មាត់សួរ ព្រោះនាងស្គាល់គេច្បាស់ ទោះពេលវេលាកន្លងទៅយូរប៉ុណ្ណា នាងនៅចំណាំស្មាគេបាន ដើមដៃគេ និងរូបរាងពីក្រោយរបស់គេ។

តែអ្វីដែលនាងចាប់អារម្មណ៍និងទុកជាអាទិភាពនៅពេលនេះគឺសុខភាពរបស់គេ។

«ហេតុអីមិនបើកបង្អួចបើកភ្លើង?»

នាងសួរជាលើកទីពីរ ហើយឈានចូលទៅតិចៗ ចំពេលគេបង្វែរកៅអីមកយឺតៗដូចគ្នា។

នារីនេះភ្ញាក់ក្រញាង តែនាងទប់សកម្មភាព មិនឲ្យបង្ហាញអារម្មណ៍រន្ធត់នេះចេញមកជាចំហ ដោយគ្រាន់តែលើកដៃមកខ្ទប់មាត់។

នៅចំពោះមុខនាង ទេវបុត្រLorenzoដែលនាងស្រមៃនឹកជាង៥ឆ្នាំមកនេះ ពុំមែនដូចកាលពីរាត្រីដំបូងដែលនាងបានរកឃើញគេនៅឯជម្រាលភ្នំនោះឡើយ។

មុខគេមួយចំហៀង ជាំខ្មៅទៅដោយស្នាមរបួសខ្មេចខ្ទាំ។

បេះដូងមនុស្សស្រីត្រូវដាច់ដោច ដូចកំពុងមានកាំបិតរាប់ពាន់ឆ្មៀលចិញ្ច្រាំ ។

នេះឬមូលហេតុ ដែលគេគេចចេញពីពិភពលោក។

នាងឈរផ្ទឹងចម្ងាយមិនដល់៥ជំហាន។ នាងលែងបន្តដំណើរព្រោះមិនចង់ឲ្យគេឃើញតំណក់ទឹកភ្នែកដែលហូរមកឆ្វាចតតមានព្រាងទុក។

«នាងមក១៤ដងហើយ?»

គេនិយាយតិចៗ តែនាងឮពេញបេះដូងមិនរបូតមួយពាក្យណាទាំងអស់។

ដោយប្រឹងលេបលាក់ក្តីទោមនស្ស សន្យានិយាយខ្សឹបៗ ព្រោះមិនចង់ឲ្យសំឡេងនាងសោយសោក។

«ខ្ញុំមិនចាំទេ! គ្រាន់តែដឹងថា ខ្ញុំត្រូវតែជួបបងឲ្យបាន!»

បុរសនេះឈ្ងោកមុខសម្លឹងតដ្ឋ។

ទុក្ខព្រួយរបស់គេ កំពុងតែសម្លាប់នាងទាំងរស់។ នាងចង់ចូលទៅ តែអ្វីមួយហាក់ដូចជាបានបង្ខាំងពួកគេ មិនឲ្យរត់រកគ្នាបាន។

គេហាក់មិនភ្ញាក់ផ្អើល គេហាក់មានវិប្បដិសារី គេហាក់មិនបាននឹកនាងចង់ជួបនាង គេហាក់ទើសទាល់ ....មិនដឹងទេ នាងរកពណ៌នាប្រាប់ខ្លួនឯងមិនកើតសោះ ដឹងតែត្រឹមថា អារម្មណ៍ពេលនេះគឺគេមិនដូចមុន....

«៥ឆ្នាំនេះ សន្យានឹកបងរហូតមក!»

នាងនិយាយរអាក់រអួល ព្រោះការបង្ខំនៃមនោសញ្ចេតនា។

បុរសនៅតែមិនងើបមុខ។

គេទ្រោបក្បាលជ្រៅជាងមុនហើយលើកដៃទាំងសងមកផ្ទប់ត្រចៀក។

សន្យា ជ្រួញចិញ្ចើម។

អ្វីទៅកំពុងកើតមានចំពោះគេ ? គេមានរឿងអី?ហេតុអីបានជាគេមិនដូចមុន?

នាងសួរភ្លាមៈ

«បងឈឺអី?ហេតុអី?»

«ខ្ញុំមាំទាំល្អបំផុត!»

គេនិយាយហើយងើបមុខមកវិញជាមួយភាពភ្លឺមុតក្នុងកែវភ្នែកទាំងសង។ វាពុំមែនជាពន្លឺភ្នែកកាចសាហាវតែក៏មិនមែនជារបៀបស្វាគមន៍មនុស្សដែលគេស្រលាញ់នោះដែរ។

នាងងឿងឆ្ងល់ នាងមិនអស់ចិត្តដែលគេអាចភ្លេចនាងបានលឿនយ៉ាងនេះ? ក្នុងពេលដែលនាងតែងតែនឹកដល់គេគ្រប់ដង្ហើមចេញចូល គ្រប់ពេលវេលានិងទីកន្លែង។

«បងធ្វើអញ្ចឹងដើម្បីអី?ហេតុអីមិនទៅរកខ្ញុំ?»

«ហេតុអី? យើងមានអីទាក់ទងគ្នា?»

គេឆ្លើយបកមកវិញរហ័ស គឺរហ័សពេករកតែនាងស្មានក៏មិនដល់ ឯចំណែកអត្ថន័យរបស់គេរឹងរឹតតែបង្ខំឲ្យស្រីតូចយើង ត្រូវស្រឡាំងកាំង។

សន្យាស្ងាត់មាត់ដូចគេចុក។

ជាមួយភាពសោកសៅ ភ្នែកទាំងគូរបស់នាង ដៀងមើលគេ ព្រោះនាងមិនអស់ចិត្ត ។ នាងនៅតែចង់ដឹងថា បុរសនេះនិយាយពិតឬកំពុងលេងល្បិចអ្វីម្យ៉ាង។

Lorenzoក្រោកឡើងសន្សឹមៗ។

នាងសម្គាល់ឃើញភ្លាម ថាគេមិនបានធាត់ មិនបានស្គមអ្វីលើសមុនប៉ុន្មានទេ ក្នុងពេល៥ឆ្នាំដែលមិនបានឃើញគ្នា។ ដំណើរគេដែលដើរមួយៗមកក្បែរនាងរឹតតែបញ្ជាក់ថា គេមិនបានឈឺ និងមិនមានបញ្ហាអ្វីទាំងអស់ក្រៅតែអំពីមុខមួយចំហៀងរបស់គេ។

នៅពេលគេចូលមកក្បែរហើយសម្លឹងនាង នាងកាន់តែផ្តោតភ្នែកលើមុខគេ ដើម្បីឲ្យដឹងច្បាស់ ថាបុរសនេះកំពុងគិតអ្វីធ្វើអ្វី។

«យើងហ្នឹង ជាអ្នកណា?»

គេនិយាយខ្លីៗហើយសម្លឹងនាងពីលើដល់ក្រោម។

ទោះពាក្យគេខ្លី តែនាងអាចផុតដង្ហើមស្លាប់បាន ប្រសិនបើមិនបានត្រៀមចិត្ត។

បេះដូង សង្វាក់សរសៃឈាមហាក់គាំងៗ ពេលឮអ្នកដែលខ្លួននឹករលឹកជាងគេ សួរមកនូវសំនួរចម្លែក។

ចុងបបូរមាត់នាង សើចបញ្ឈឺឲ្យភាពឈឺចាប់។

៥ឆ្នាំហើយ សន្យាមិនមែននៅជានារីក្មេងល្ងក់ វ័យ២០ឆ្នាំទៀតដែរ។

ស្រីតូចដ៏ស្រស់បំព្រងនៅផ្ទះអនាគត បានឆ្លងកាត់ការឈឺចាប់ អាណោចអាធ័មច្រើនហួសហេតុពេកហើយ តែបេះដូងនាងនៅតែចចេសចងចាំមនុស្សប្រុសម្នាក់ ដែលនាំមកឲ្យខ្លួននូវការឈឺចាប់ទាំងនេះ។

«ល្អមើលពេកហើយ Lorenzo»

នាងនិយាយទាំងងាកភ្នែកចេញ ហើយដៃទាំងពីរច្រានគេភឹង។

រាងកាយបុរសនេះថយក្រោយប៉ុន្មានធ្នាប់ដៃ តែក៏មិនរង្គើប៉ុន្មានដែរ។

នាងញញឹមឈឺចាប់ហើយសម្លក់នាយដោយកែវភ្នែករលោង។ សំឡេងនាងបញ្ចេញមកបន្ថែមកំដរទឹកមុខស្មើគ្មានមនោសញ្ចេតនារបស់នាយ៖

« ប្រាកដអត់? ថាអត់ស្គាល់ខ្ញុំ?»

បុរសនេះសម្លឹងនាងដល់ក្នុងជម្រៅប្រស្រីភ្នែក។ គេហាក់រកនឹកហើយរកនឹកទៀត។ គេហាក់យល់ថា នាង ជាអ្នកណាម្នាក់ដែលនឹកមិនឃើញ តែមានអារម្មណ៍ថាពាក់ព័ន្ធ។

ហេតុអីនាងឱ្យៗ ហើយមើលទៅមានទុក្ខដ៏ជ្រៅ?

ហេតុអីសំឡេងនាងហាក់បីដូចជាអ្វីមួយពាក់ព័ន្ធនឹងដួងវិញ្ញាណនាយតែសម្ដីនាងមួយម៉ាត់ៗគ្មានអ្វីមួយគួរឲ្យយកជាតម្រុយសន្និដ្ឋានបាន?

គេដកដង្ហើមធំ។

«សូមទោស!»

ពាក្យសូមទោសរបស់អ្នកពេលខ្លះវាខ្លីហើយវាស្រួលនិយាយចេញមកណាស់ តែសម្រាប់អ្នកទទួលវាដូចជាកាំបិត វាប្រៀបបាននឹងគ្រាប់សំណឬអាចជាមច្ចុរាជដែលអ្នកកំពុងតែបញ្ជូនមកឱ្យ។

នាងញញឹមទាំងទឹកភ្នែក......តាមពិតខ្លួនក៏ដឹងដែរថា ប្រសិនណាបើមិនចូលមកល្អជាង ព្រោះធ្លាប់ត្រូវគេបដិសេធច្រើនលើកមកហើយ ។

លើកនេះបានចូលមកជួបគេមែន តែវាយ៉ាងម៉េច? មានតម្លៃដែរទេ? ពាក្យសូមទោសពីរម៉ាត់ជាអំណោយសម្រាប់ការជួបគ្នាដំបូងបន្ទាប់ពីបានរក្សាចិត្តស្មោះរស់នៅដោយឯការង់ចាំគេ?

«នេះមិនមែនរឿងកុន បងមិនចាំបាច់សម្ដែងក៏បានដែរLorenzo»

មិនដឹងយ៉ាងម៉េចបានជាខាងបុរសចង់ងាកមុខចេញចោលភាពទុក្ខសោករបស់នាងតែគេនៅតែមិនដាច់ចិត្ត។

ទឹកភ្នែកនាងរមៀលចុះមកថ្លាដូចពេជ្រចរណៃ ហើយសម្ដីអួលៗនេះដូចជាអាចប៉ះទង្គិចអ្វីដល់បេះដូងនាយដែលហាក់លែងចេះឈឺ លែងចេះរំញោចជាយូរណាស់មកហើយ។

បបូរមាត់នាងញ័រ ហើយសស្លេក។

ភ្នែកនាងស្រពោនគឺស្រពោនជាងទឹកមុខនាយដែលរស់មកក្នុងភាពជាមនុស្សមិនស្គាល់ខ្លួនឯងរាប់ឆ្នាំមកនេះទៅទៀត។

«យូរណាស់ហើយដែលយើងមិនអាចញញឹមចេញ ក៏មិនដែលដឹងទុក្ខកង្វល់ ដល់ថ្នាក់ត្រូវយំបានចុះហេតុអីទឹកភ្នែកនាងម្នាក់នេះ នៅវិនាទីនេះ ធ្វើឱ្យយើងមានអារម្មណ៍ហាក់ដូចបានជំពាក់អ្វីម្យ៉ាងពីនាង?»

គេគិតទាំងកែវភ្នែកបួនរង្វង់ប្រទាក់ចូលគ្នា។ បុរសហារស្នូរតិចៗឆ្ពោះទៅរករោមភ្នែកងរខ្នែតដែលមូលក្រឡង់ចំពោះមុខ៖

«យើងនេះ ជាបងស្រីរបស់ពិនណា?!»

នាងរវេក្នែកចេញវិញនិម្មិតតែស្ដាប់ឮឈ្មោះខ្លីដែលធ្វើឱ្យនាងឈឺចាប់។ នៅមិននៅ ខ្លួនក្លាយជាកូនស្រីច្បងរបស់ផ្ទះអភិជនផ្នែកហិរញ្ញវត្ថុដ៏ធំជាងគេនៅភ្នំពេញហើយពិនណាបានក្លាយមកជាប្អូនស្រីភ្លោះរបស់ខ្លួន ។ ទោះបីជាកូនស្រីភ្លោះពីរនាក់នេះមានមុខមាត់មិនដូចគ្នាក៏មិនសមណា គេមានចិត្តមកលើបុរសតែម្នាក់ជាមួយនាងឡើយ។

ម្ភៃឆ្នាំហើយនាងត្រូវបានជំរត់ទៅរស់នៅព្រៃភ្នំក្រំថ្ម ពេលបានទទួលស្គាល់គ្រួសារវិញសមណាស់តែមានសុភមង្គល ដឹងអីគ្រប់យ៉ាងទៅជាដូច្នេះ។

ផែនដីតូចចង្អៀត សង្សារវិលមកវិញ តែគេមកក្នុងនាមជាបុរសម្ចាស់បេះដូងអ្នកផ្សេងដែលនៅកៀកនឹងខ្លួនបង្កើយ?

សន្យាមិនសុខចិត្ត ទោះបីយ៉ាងណានាងមិនជឿការពិតដ៏កាចសាហាវទាំងនេះឡើយបានជានាងស្កាត់រកគេម្តងហើយម្តងទៀត ទាំងទទួលការបដិសេធជានិច្ចមកនៅតែនាងមិនព្រមបោះបង់ចោល។

«កុំនិយាយរឿងផ្សេង!កុំសួររឿងផ្សេង ក៏កុំនិយាយរឿងដែលមិនទាក់ទង! សួរមក ថាខ្ញុំជាសង្សាររបស់ខ្លួនពិតមែនដែរអត់!»

ទុក្ខព្រួយលេចឡើងក្នុងកែវភ្នែកបុរសនេះ។ គេលេបទឹកមាត់បញ្ចេញសញ្ញាតាមបំពង់កធំមាំនិងសរសៃសសូងក្នុងភាពជាមនុស្សប្រុសក៏ជាសុភាពបុរស ហើយចរន្តឈាមក្នុងរាងកាយគេកំពុងរត់ប្រសាចចុះឡើងផ្តល់សញ្ញាកក់ក្តៅមួយចូលទៅក្នុងប្រអប់បេះដូងដ៏រងរបួសនេះ។

តែមាត់គេបដិសេធះ

«យើងមិនមែនទេ!»

គេនិយាយអញ្ចឹងមែនតែភ្នែកនរៈ នៅតែជាប់ផ្សារភ្ជាប់នៅក្នុងចំណុចប្រស្រីខ្មៅក្រឹបនៃនារីជាភ្ញៀវ។ នេត្រានាងរលើបរលោងព្រមពេលបេះដូងនាង លោតភាំងៗ សឹងថា ដួលស្លាប់ព្រោះតែខំទប់ទល់នឹងការឈឺចាប់អស់សង្ឃឹមលើសម្តីនាយ។

រកពាក្យនិយាយមិនបាន ដែលសម្លឹងគ្នាបែបនេះហើយគេនៅតែមិនទទួលស្គាល់ការពិត ស្រីស្អាតខាំមាត់ហើយចចេសស្រវាតោងស្មាគេ។

ដៃនាងទាំងទ្វេលោមករកបុរសខ្ពស់ស្រាវហើយជើងនាងជំទើតមករកភក្ត្រមនុស្សម្នាក់ដែលនាងបាននឹកគេអស់រយពាន់រាត្រីមកហើយ។

«បើបបូរមាត់យើងប៉ះគ្នា បងប្រហែលអាចចាំបានមែនទេLorenzo!»

ស្រីស្អាតគិតហើយក៏ធ្វើព្រោះមានៈ ។ នាងយល់ថាការពិតគឺការពិត ព្រោះនាងជាអ្នកត្រូវដូច្នេះនាងមិនខ្លាចអ្វីទាំងអស់ ចំណែកកាលដែលនាងគិតថាគេព្រមឈរស្ងៀមឱ្យនាងថើប គឺជារឿងគួរឱ្យហួសចិត្តមួយ។

រហ័សដូចផ្លេកបន្ទោរ LorenZoងាកគេចមុខចេញ ហើយដៃគេជាបន្ទាន់គ្នានោះស្មាគេក៏គ្រវាសបដិសេធហត្ថាទាំងសងនៃនារីដែលលោមករកគល់កដូចគ្នា។

នាងតោងគេមិនជាប់ទេព្រោះគេមិនចង់។

ដៃនាងរបូត ហើយជំហរនាងក៏មិនមាំ រាងកាយរាវតូចស្គម ភ្លាត់ជំហរទៅមុខ ទន់ជើងដួលរេលទៅលើកម្រាល។

គេនៅឈរស្ដឹង ពីក្រោយនារី។

គេមិនងាកមកនាងក៏មិនងាកទៅ។

តើវាគួរឱ្យអៀនខ្មាសដែលមនុស្សស្រីម្នាក់បែរជាចង់ថើបត្រកងបុរសជាសង្សាររបស់ខ្លួនមុន? អូទេ ដែលគួរឱ្យអាម៉ាស់គឺនាងត្រូវបានគេបដិសេធ។

ម្ដងហើយម្ដងទៀតឯងត្រូវបានគេបដិសេធជានិច្ចណ៎ា សន្យា ស្រីល្ងង់។

«បងភ្លេចខ្ញុំហើយLorenzo មនុស្សចម្លួត កោតណាស់! បងភ្លេចអស់ហើយ!»

នាងនិយាយអួលៗ ទាំងឈឺចិត្តទាំងអស់សង្ឃឹម និងគ្មានកម្លាំងសូម្បីនឹងក្រោកឡើង។

នាងជូតទឹកភ្នែក ពេលដែលខាងប្រុសបែរមកសន្សឹមៗហើយគេក្រឡេកមើលនាង។ គេអោនមកនាងទាំងលូកដៃមកឱ្យស្រីតោង ព្រោះចិត្តអាណិតដែលលេចឡើងមិនដឹងតាំងពី ពេលណា។

សម្ដីបុរសលាន់មកស្រាលៗ ជាមួយនឹងកែវភ្នែកស្លូតបូត៖

«ឈប់ធ្វើអញ្ចឹងទៅវាមិនល្អទេ!»

នាងមិនទទួលដៃនាយរឹតតែមិនព្រមក្រោក។

សន្យាអង្គុយស្រក់ទឹកភ្នែក។

មាត់នាងខាំមិនព្រមអនុញ្ញាតឱ្យសម្រែកសោកសៅលាន់ឮមកនូវសូរសព្ទសោយសោកសូម្បីបន្តិចណាធ្វើឱ្យឱរាបុរសកាន់តែតឹងសឹងប្រេះបាន។

ហេតុអ្វី?

គេចាប់ផ្ដើមវិលវល់ !!

តើកាលដែល បដិសេធស្នាមថើបរបស់នាងធ្វើឱ្យមនុស្សស្រីម្នាក់ឈឺចាប់យ៉ាងនេះ?

បុរសអង្គុយចុះសន្សឹមៗក្បែរនាង។ សាជាថ្មី គេលើកហត្ថាទាំងទ្វេ មកត្រកងនាងឡើង នាងចាប់ផ្ដើមវាយតបជាកិច្ចព្យាយាមប្រកែកជាមួយជំនួយរបស់បុរសដែលនាងយល់ថាគ្មានធម៌មេត្តា ប៉ុន្តែគេមិនព្រមតាមចិត្តនាងគេនៅតែចង់ស្ទួយនាងឡើងមក។

«ឈប់ឆេវឆាវទៅ សន្យា!»

ស្រីតូចនៅភាំងផ្អឹងគ្រាន់តែគេហៅនាងចំឈ្មោះហើយហៅស្រាលៗ ។ សំឡេងគេមិនដូរទេ។ពីមុនក៏អញ្ចឹងតឡូវក៏បែបហ្នឹង។គឺការហៅមួយនេះដែលនាងបានចងចាំទុកក្នុងបេះដូងរហូតមក។

ដៃនាងទាំងពីរថ្ពក់ជាប់នឹងដៃនាយ  ពេលនាងភាំងគេក៏ភាំង។ បបូរមាត់ដែលខានញញឹមច្រើនឆ្នាំស្រាប់តែ ភ្លាត់ចេញផ្កាញញឹមតិចៗ ??ពិតមែនហើយ យើងញញឹមបានវិញហើយ គឺញញឹមព្រោះឃើញនាងកំពុងញញឹម។ស្រីម្នាក់នេះសែនចម្លែក គ្រាន់តែយើងហៅឈ្មោះគេ គេក៏ញញឹមបានភ្លាមទាំងដែលកំពុងយំ?

«ទីបំផុត យើងបានប៉ះសាច់ហាប់ណែនលើកំភួនដៃគេវិញហើយ!»

នាងគិតហើយរវេគ្នែកទៅរកប្រុសទ្រូង៥ហត្ថដែលនៅកៀកនឹងច្រមុះ ហើយដៃទាំងបួនស្រាក់ចូលគ្នា។ ម្រាមស្រលូនដូចបន្លាក្រូចនៃនារីនេះប្រឹងចចេសប៉ះពាល់ស្បែកនាយសូម្បីតែមួយចំណែកតូចក៏នាងធ្វើ។

យើងប៉ះគេហើយ គេមានអារម្មណ៍ដឹងនិងនឹកឃើញអតីតកាលខ្លះដែរទេ?

នាងគិតទាំងញញឹមក្នុងបេះដូង បណ្តោយឱ្យម្រាមដៃជាប់ខ្មាស់ធ្វើចលនាតាមដែលអាចធ្វើទៅបានលើសាច់ដុំកំភួនដៃនៃបុរសម្ចាស់បន្ទប់។

គេទំនងជាខានមានអារម្មណ៍បែបនេះជាយូរមកហើយ។អារម្មណ៍ដែលត្រូវបានប៉ះពាល់ដោយមនុស្សស្រីជាមួយម្រាមតូចស្តួចវែងបែបនេះបានជាគេនៅផ្ទាំងហើយសន្សឹមៗ គេអោនក្រឡេកមើលទៅទីនោះ។

មួយប៉ប្រិចភ្នែកប៉ុណ្ណោះ នាងងើយមុខទៅជាមួយចេតនា ពិតក្នុងការបណ្តោយឱ្យបបូរមាត់ខ្លួនបុកប៉ះផែនថ្ពាល់ក្រៀមស្រពោនរបស់នាយ ។

មុខគេរបួសយ៉ាងនេះ ហេតុអ្វីស្នាមថើបមនុស្សម្នាក់នេះ ធ្វើឱ្យគេចេញចំហាយក្តៅដោយក្តីអៀនប្រៀនហើយ នៅគាំងចលនាបាន?

ដៃគេកំពុងស្រាក់ដៃនាង តែគេធ្វើភាំងដូចកំពុងត្រូវបាននាងគ្រប់គ្រង។

«នឹកឃើញដែរទេ? ថ្ងៃដែលបងសុំឱ្យអូនថើប?!»

គេដៀងភ្នែកមករកកែវភ្នែកស្រងូតនិងអន្ទះសារង់ចាំចម្លើយរបស់នាង ។ ត្បិតគេនៅស្ពឹកៗព្រោះអារម្មណ៍អៀនប្រៀននិងព្រឺព្រួចតែកែវភ្នែកនាងម៉ក់ៗនៅចំពោះមុខពិតជាស្អាតពេកពិតក្នុងចិត្តអ្នកជំងឺ។

នាងព្រិចភ្នែកទទូចរង់ចាំចម្លើយ បុរសនេះនៅតែភាំង.....

ធ្វើឱ្យស្រីស្អាតថ្លោះទឹកមុខ ហើយប៉ប្រិចភ្នែកខូចចិត្ត។

«គេភ្លេចហើយ!គេនឹកមិនឃើញទេ!»

នាងនិយាយប្រាប់ខ្លួនឯងទាំងអស់សង្ឃឹមក្នុងចិត្ត។ សន្សឹមៗនាងលែងដៃពីគេតែគេនៅតែមានះតោងជាប់ម៉ឺង។

«បងភ្លេចអស់ហើយ! »

នាយគ្រវីក្បាលតិចៗព្រោះមិនដឹងថាតើអ្វីទៅដែលបណ្តាលឱ្យគេចង់មើលនាង ហើយចង់អង្គុយជិតនាងរបៀបនេះចិត្តគេក៏ចង់សួរនាងតែគ្មានសំណួរ ចិត្តគ្មានចម្លើយ គេភ្លេចនាងឬមួយគេមិនដែលស្គាល់នាងពិតមែន តើអ្វីទៅនៅពីក្រោយឆាកនេះ។

អ្នកណាម្នាក់កំពុងសម្លឹងមើលមកពួកគេ។ អ្នកទាំងពីរកំពុងតែចូលតួសឹងភ្លេចថា អ្នកនាំផ្លូវអម្បាញ់មិញបានចូលមកដល់ហើយ។ ១៥នាទីរបស់នាងអស់ហើយ។

អ្វីដែលត្រូវធ្វើក៏បានធ្វើរួចហើយដែរចុះម៉េចក៏គេនៅតែនឹកមិនឃើញ។

មិនបាច់បែរក្រោយទេ សន្យាដឹងថា អ្នកនាំផ្លូវអម្បាញ់មិញមកទារយកពេលវេលារបស់គេវិញហើយ។

នាងលើកដៃជូតទឹកភ្នែក។ ភាពរឹងមាំរបស់នាង មិនមែនដូចកាលពី៥ឆ្នាំមុនឡើយ តែល្មមឱ្យម្ចាស់បន្ទប់ជ្រួលច្រាល់ក្នុងចិត្តបាន។

នាងរុញដៃគេចេញបានសម្រេចព្រោះLorenzoឈប់ប្រទាញ។

នាងក៏ក្រោកមក គេក៏ក្រោកមក។

«គេឈឺអីទៅ?គេមានរឿងអីបានជាក្លាយជាមនុស្សគ្មានការចងចាំអីទាំងអស់?!»

នាងសួរទាំងគ្មានអ្នកឆ្លើយ ទាំងក្តៅចិត្តទាំងLorenzoកំពុងមើលមកនាងដូចមនុស្សចម្លែក។

នាងងក់ក្បាលទាំងសៅហ្មង ហើយបែរក្រោយរកអ្នកនាំផ្លូវ។

«ខ្ញុំសួរថា មានរឿងអីកើតឡើងចំពោះគាត់? គ្រប់គ្នាធ្វើអ្វីគាត់បានជាគាត់ក្លាយទៅជាអញ្ចឹងបាន? បងនិងពិនណា និយាយអីនឹងគាត់បានជាគាត់មិនស្គាល់ខ្លួនឯងសោះ?»

បុរសម្នាក់នោះជ្រប់មុខមិនឆ្លើយ ធ្វើឱ្យចិត្តស្រីរឹតតែពុះពោរ។

នាងនិយាយបន្ថែមចុងក្រោយ៖

«បើគាត់មិនដឹងខ្លួនផង ហេតុអ្វីគ្រប់គ្នាចាប់គាត់ឱ្យរៀបការជាមួយអ្នកដែលគាត់មិនស្រលាញ់? អ្ហះ?»

បុរសនោះស្រាប់តែងើបមុខតវ៉ាវិញដោយភាពមាំទាំ៖

«អ្នកនាងវីរីណាប្រយ័ត្នសម្ដី!អ្នកនាងពិនណាជាប្អូនស្រីបង្កើតរបស់អ្នកនាង»

ស្រីស្រស់លេបភាពជូរចត់។

មុនពេលចាកចោលទីកន្លែងដ៏ឈឺចាប់នេះនាងងាកមកសម្លឹងគេជាចុងក្រោយ។ គេស្រងូត តែគេមិនបាននិយាយអ្វីថែមទាំងបែរខ្នង។តើនាងនៅមានន័យអីទៅ?

មនុស្សគ្រប់គ្នានៅទីនេះជាខ្នងបង្អែករបស់ពិនណា។ស្នេហានាងនិងLorenzoគ្មានអ្នកណាដឹងគ្មានអ្នកណាព្រមធ្វើជាសាក្សីទេ រឹតតែសំខាន់គឺគេនេះមិនទទួលស្គាល់នាងដោយខ្លួនឯងតើនៅមុខក្រាស់ឱ្យគេមាក់ងាយថាចែចង់គូដណ្ដឹងប្អូន?

ស្រីស្អាតចាកចេញរឹង មិនបន្សល់សូម្បីពាក្យលា។

មួយម៉ាត់ក៏មិននិយាយ.....នាងខឹង នាងលែងមកហើយមែនទេ? នាងស្អប់យើង?

គេសួរសំនួរទាំងបីក្នុងទ្រូង ទាំងមិនដឹងផងថាហេតុអ្វី?

១៤លើកហើយ គេមិនដែល ចង់ជួបនាងចុះហេតុអ្វីពេលនេះ ពេលបានឮសម្ដីនាង និយាយនឹងនាងប៉ុន្មានម៉ាត់ ហើយឃើញនាងចាកចេញទាំងអញ្ចឹងនាយ ខ្លួនឯង បែរជាមានអារម្មណ៍ដូចខុសៗ?

«ខ្ញុំត្រូវការដឹងឱ្យស៊ីជម្រៅ អំពី រឿងខ្ញុំពីមុនជាមួយមនុស្សស្រីម្នាក់នេះ»

គេនិយាយតិចៗតែមិនបែរមកកាន់គូសន្ទនាទេ។

ជំនួយការដកដង្ហើមធំ មុនពេលសម្រេចចិត្តឆ្លើយមួយៗ៖

«សន្យាជាបងស្រីរបស់អ្នកនាងពិនណា ដែលធ្លាប់ត្រូវគេជំរត់ចេញពីផ្ទះ តាំងពីតូចមក!ក្រោយពេលរកឃើញវិញ ឮលោកអគ្គនាយកថា គាត់មានបញ្ហាផ្លូវចិត្ត! »

«ផ្លូវចិត្ត?»

គេងាកមកជាមួយចិញ្ចើមជ្រួញ។

ទោះយ៉ាងណា ជំនួយការម្នាក់នេះ មើលមិនឃើញភាពភ័យខ្លាចឬស្អប់ខ្ពើមលើទឹកមុខចៅហ្វាយនាយសង្ហាទាល់តែសោះ បែរជា គេរកឃើញនូវភាពឈឺឆ្អាលសម្ងាត់មួយទៅវិញ?

ក្រែងLorenzoបាត់ការចងចាំហើយ?

ក្រែងគេជិតរៀបការនឹងពិនណាហើយ ថែមទាំងដឹងថាស្រីម្នាក់អម្បាញ់មិញមានរោគចិត្តទៀត

នៅតែគេមិនស្អប់នាងតិចតួចសោះក្នុងភ្នែកគេ?

ហេតុអ្វី?

**មនុស្សបន្លំ**

ជំនួយការត្បាញអាយម្នាក់នេះមិនយល់អំពីស្នេហាទេ។

គេមិនយល់ទេថា តើរវាងមនុស្សពីរនាក់ដែលធ្លាប់ស្រលាញ់គ្នា ទោះស្លាប់ទៅជាខ្មោចក៏នៅចងចាំគ្នាបាន ចុះហេតុអ្វីគ្រាន់តែវង្វេងប៉ុណ្ណឹង នឹកគ្នាមិនឃើញ?

គេគិតខុសហើយ ដែលប្រថុយឱ្យនាងបានជួបគេ បន្ទាប់ពីពង្វាងគ្នាបានដល់ទៅ៦ឆ្នាំ។

ល្ងាចស្អែកថ្មី គេឃើញបុរសរូបសង្ហាLorenzoនៅក្នុងហាងអាហាររ៉ូមែនទិកមួយដែលរៀបចំយ៉ាងពិសេសសម្រាប់តែនាយនិងគូដណ្តឹង។

ភ្ញៀវដទៃ មិនត្រូវបានអនុញ្ញាតឱ្យចូលមកទេ នេះជាទម្លាប់រ៉ូមែនទិកដ៏ក្អេងក្អាងរបស់ពួកអភិជននានា ក្នុងសង្គមជាន់ខ្ពស់ ។

បុរសនេះនិយាយមួយៗទាំងមុខស្រពោន៖

«ក្រោយៗមិនចាំបាច់ប៉ាវហាងអង្គុយតែយើងទេ មានគេឯងផងក៏បាន !»

គេមិនបាននិយាយចប់ទេ តែនាងអន់ចិត្តព្រោះសម្តីគេ ដូចជាកំពុងបន្ទោសពិនណាពីការខ្ជះខ្ជាយរបស់នាង។ គេនេះប្តូរចរិត ប្តូរទម្លាប់ ប្តូរការគិត ស្រលះពីមុន។

នារីអភិជន លបលួចគិត ពីក្រោមស្នាមញញឹមស្រស់តែចិត្តនាងពិតប្រាកដគឺកំពុងកញ្ជ្រោលក្ដៅ។

ព្រឹកម្សិលមិញគេបានជួបសង្សារចាស់នាងដឹងច្បាស់ព្រោះដៃជើងនាងជួលមកស្នេកស្ទុះសម្រាប់តែឃ្លាំលប្រុសម្នាក់នេះ ។

នាងខឹងបំផុតគឺ  បន្ទាប់ពីបដិសេធ មិនជួបសន្យា ដល់ទៅ១៤លើក ទីបំផុត ខ្មោចអីជំរុញគេ ឱ្យព្រមជួបនាងទាល់តែបាន?

បើតាមសម្ដីជំនួយការជារនុកក្នុងម្នាក់នោះមករាយការណ៍គឺ គេហាក់មិនព្រមកាត់ចោលស្រមោលមនុស្សស្រីម្នាក់នោះចេញពីការគិតសោះ បន្ទាប់ពីពេលជួបគ្នារួចហើយ។

នេះជាដើមចមដែលនាងនៅលែងសុខ ត្រូវតែសុំគេចេញមកហូបបាយល្ងាចបែបលន្លង់លន្លោច។

ពិនណា នៅតែសង្ឃឹមថា បរិយាកាសរ៉ូមែនទិកនេះនឹងចូលមក កសាងជម្រៅស្នេហ៍រវាងនាងនឹងគេលុបពីលើអតីតកាល ទាំងប៉ុន្មាន ដឹងអីគេមិនមានចរិតកប់មេឃ ដូចទេវបុត្រសប្បុរសLorenzoដែលពីមុនរមែងឆ្មើងកន្ទ្រើងហ៊ឺហា ចាយលុយរាប់លាននោះទៀតសោះ?

«ចាយប៉ុណ្ណឹង អនាគតស្វាមីរអ៊ូទៅហើយ!»

ពិនណាវាចាឌឺដងតិចៗ លាក់បាំងកំនួចនៃចិត្តដែលពិសពុលកញ្ជ្រោលបោកបាច ពី កែវ ភ្នែក Lorenzo។

គេមិននិយាយអ្វីច្រើន បានត្រឹមបំបែរទៅចាប់សាច់ឱ្យនាងជំនួសប្រតិកម្មចម្លើយ។

ចំពោះកែវភ្នែក Lorenzo ទោះបើ នារីអភិជនម្នាក់នេះ ប្រើសូត្រពណ៌ស រលើបក្រោមម៉ាកយីហោកប់ពពកដូចកំពុងបង្ហាញខ្លួនលើព្រំក្រហមនៅក្រុងកាន ហើយពន្លឺហ្វាភ្លើងពណ៌ស្វាយខ្ចីស្រទោស្រទន់ត្រូវបានរៀបចំមកដើម្បីបង្កើនសម្រស់នាង ក៏ នាងនៅតែមើលទៅហាក់បីដូចជា គ្មានកន្លែងណាទាក់ជ្រៅក្នុងជម្រៅបេះដូងដូចទឹកមុខស្រងេះស្រងោចរបស់បងស្រីនាងកាលពីម្សិលឡើយ។

ហេតុអ្វីយើងនៅតែនឹកឃើញទឹកភ្នែកមនុស្សស្រីចម្លែកកាលពីម្សិល?

គេគិតចុះឡើងមុនពេលសម្រេចចិត្តសួរស្រាលៗទៅកាន់គូដណ្ដឹងក្នុងភាពជាបុរសថ្លៃថ្នូរ៖

«ពិនណា!បងស្រីរបស់អូន គេហ៍.....!»

ពិនណាទច់បង្អង់ដៃដែលកំពុងប្រុងថាចាប់ម្ហូបសងគូដណ្ដឹង។

ទោះបី នាងប្រឹងសម្ដែងប៉ុណ្ណា ពូកែប៉ុណ្ណានៅតែលាក់ពីភ្នែក អ្នកប្រុសមិនបានទេ ថាចិត្តមានសម្ពាធពេលឮអ្វីក៏ដោយជុំវិញមនុស្សស្រីម្នាក់នោះ។

ពិនណា ស្អាតណាស់ ពេលងើបមុខឡើងមក។

ខ្សែកពេជ្រ ប្រាក់លានរបស់នាង ចាំងព្រាកៗ អួតបង្ហាញ នូវភាពខ្ពង់ខ្ពស់នៃត្រកូលហង្សាពីកំណើត ប៉ុន្តែបងស្រីនាងដែលតែងតួដូចមនុស្សខូចចិត្ត  មានភាពសម្ងាត់និងជ្រាលជ្រៅគួរឱ្យចង់ដឹងជាង។

ទៀតហើយ!

មនុស្សដូចយើងទៅគិតពីស្រីម្នាក់ៗចម្លែកៗហ្នឹង?

Lorenzoបន្ទោសបេះដូងនាយទាំងភ្នែកកំពុងសម្លឹងទៅស្រីស្រស់ជាគូនៅចំពោះមុខ។

ជាធម្មតា គេឯណាទៅចង់  រំឭករឿងបងស្រីរោគចិត្តរបស់នាងនៅក្នុងបរិយាកាសបែបនេះ ?តែចិត្តមួយបែរជាមិនស្ដាប់បញ្ជា ព្រោះរយៈពេលចាប់ពីជួបនាង ខួរក្បាលនាយវិលចុះឡើងជុំវិញតែសំណួរនានាអំពីនាង?

ប្រុងថានឹងនិយាយដូរបរិយាកាសវិញ តែពិនណាឆ្លើយព្រមទាំងញញឹមមកមុន៖

«ម្សិលមិញបងវីរីណាទៅរកបងLorenទៀតហើយ?»

វីរីណាជាឈ្មោះពិតរបស់នាង មុនត្រូវចាប់ពង្រត់ចេញពីគ្រួសារ។ ចំណែកសន្យាជាឈ្មោះអ្នកភូមិក្រីក្រនោះដាក់ឱ្យ។

Loirenzo ដឹងរឿងនេះតាមរយៈជំនួយការដែលជានិច្ចជាកាលឃាត់នាយមិនឱ្យជួបស្រីម្នាក់នោះ ព្រោះសំអាងហេតុផលថា នាងមានវិបត្តិផ្លូវចិត្ត ធ្ងន់។

ពួកគេនិយាយថា តាំងពីវិលមកផ្ទះវិញ វីរីណាតែងតែច្រណែននឹងសុភមង្គលនានាដែលពិនណាមាន ។

អ្វីដែលនរៈបានដឹងគឺ ស្រីឈ្មោះសន្យាឬវីរីណា បានព្យាយាមបំផ្លាញពិនណាសូម្បីតែរឿងអាពាហ៍ពិពាហ៍មួយនេះ។

«បងស្រីអូនមាននិយាយអីផ្ដាសដាក់បងខ្លះLoren?!»

Lorenzo មិនចរចាអ្វីជាចម្លើយមកកាន់គូដណ្ដឹងទេ។

គេសម្លឹងកែវភ្នែកថាំងព្រាកៗរបស់នារីដែលកំពុងមានវត្តមាន ចំពោះមុខខ្លួន។

សាជាថ្មីចិត្តគេចាប់រោរា និងរារែក។

គេ ទៅជានឹករំពៃ ដល់សម្តីកាលពីម្សិលមិញ «ហេតុអីមករស់នៅកន្លែងអញ្ចឹង?»«ហេតុអីមិនបើកបង្អួចបើកភ្លើង?»

គេលើកដៃស្ទាបមុខរបួសពេលដែលនឹកឃើញពីភាពអាណិតអាសូរជាសម្ងាត់ដែលមនុស្សស្រីម្នាក់កាលពីម្សិលផ្ដល់មកឱ្យខ្លួន។ នាង នៅក្នុងការចងចាំរបស់គេ មិនសមនឹងមានរោគចិត្ត មិនសមជាមនុស្សស្រីដែលបំផ្លាញពិនណា ក៏មិនសមថាជាមនុស្សអាក្រក់សោះ។

«ខ្ញុំមិនចាំទេ! គ្រាន់តែដឹងថា ខ្ញុំត្រូវតែជួបបងឲ្យបាន!»

សាជាថ្មី តារាសប្បុរសឈ្ងោកមុខសម្លឹងឥដ្ឋ។

គេមិនដឹងទេថា ទុក្ខព្រួយរបស់គេ កំពុងតែចាក់ឆ្កឹះភ្លើងប្រចណ្ឌច្រណែនក្នុងចិត្តពិនណា។

នាងឈឺចាប់ដែលប្រុសស្អាតនៅតែរវល់នឹងស្រមោលស្រីម្នាក់នោះ រហូតដល់ដៃប្រឹងក្ដាប់ បើមិនអញ្ចឹងនាង នឹងស្រែកផ្អើលអស់មនុស្សតូចធំដែលបម្រើការក្នុងហាងនេះមិនខាន។

«៥ឆ្នាំនេះ សន្យានឹកបងរហូតមក!»

សំឡេងនាងលាន់មកជានិច្ច គឺគ្រប់ពេលវេលាគ្រប់ទីកន្លែង។ គេកាន់តែនឹកនាង ព្រោះសម្តីនាងតិចៗ តែវាចូលជ្រៅក្នុងបេះដូងរបស់គេ រហូតដល់គេភ្លេចនូវសំនួរនិងល្បិចរបស់ស្រីឆ្នាសម្នាក់នៅចំពោះមុខ ឯបេះដូងវិញជិតដាមតែសម្តីកូននាគតូចដ៏កម្សត់។

ទោះយ៉ាងណាគេមិនអាចស្ងៀមបានយូរឱ្យពិនណាសង្ស័យទេ គេត្រូវតែសាសង។ Lorenzoពោលសួរតិចៗក្រោមកែវភ្នែកកាចសាហាវរបស់កូនស្រីអ្នកមាន៖

«ពិនណា ប្រាប់បងមក! បងធ្លាប់ស្គាល់បងស្រីអូនទេ?ស្គាល់កម្រិតណាដែរ?!»

ពិនណាអាចនឹងស្រែកដាក់នាយម្ដងៗ តែនាងទប់ចិត្ត នាងជិតរៀបការហើយចុងក្រោយនាងនៅតែជាកូនក្រមុំរបស់គេដូច្នេះការអត់ធ្មត់គឺជាដើមទុនដ៏ចាំបាច់មួយក្នុងគ្រានេះ។

ដើម្បីកុំឲ្យនាយមើលឃើញប្រតិកម្មលើមុខ ស្រីស្រស់ធ្វើជាលើកកន្សែងសមកជូតមាត់ តែតាមពិតនាងខំទប់ចិត្តនិងរក្សាទឹកមុខស្រស់ប្រិមប្រិយ។

ស្រីស្អាតឆ្លើយស្រាលៗ៖

«នៅមិននៅមកចង់ដឹងរឿងមិនសប្បាយចិត្តទៀតហើយ? ប្រាប់ហើយថាគាត់ទើបរើមកនៅផ្ទះវិញបានប្រហែលប៉ុន្មានខែ! បន្ទាប់ពីទៅនៅខ្វាត់ព្រាត់ក្រៅផ្ទះ អស់ម្ភៃឆ្នាំ! មកវិញគាត់ខឹងប៉ាហើយខឹងខ្ញុំគាត់ចង់ដណ្ដើមសូម្បីភាគហ៊ុនធំនៅOCហើយនឹង ចុងក្រោយ ឃើញបងLorenគាត់ក៏ ......»

នាងនៅស្ងៀមពេលគេមើលមកខ្លួនមុតពេក។

ច្រើនដងហើយដែលបុរសនេះធ្លាប់ឮនាងនិយាយថា បងស្រីរោគចិត្តចង់ស្រលាញ់អនាគតប្អូនថ្លៃ ហើយបងស្រីម្នាក់នេះអាចនិយាយរឿងកុហកសព្វសារពើដើម្បីបំផ្លាញពិនណា ម្ល៉ោះហើយLorenzo មិនដែលព្រមឱ្យនាងជួបឡើយ។

ម្សិលមិញជាអព្ភូតហេតុ ។

គេនឹកឆ្ងល់ហេតុអ្វី ក៏មនុស្សស្រីរោគចិត្តម្នាក់ តស៊ូម្ល៉េះ។

ចុះហេតុអ្វីបានជួបគេហើយមិនឃើញនិយាយអ្វីប្រឆាំងនឹងពិនណា?ឃើញតែនិយាយពាក្យខ្លីៗ ដែលស្ដាប់ហើយ លន្លង់លន្លោចឈឺចាប់ជំនួស?

«ល្មមមើលពេកហើយ Lorenzo»

សំឡេងគេលាន់មកក្នុងការចងចាំ របស់នាយហើយដៃទាំងពីររបស់នាងដែលច្រានគេភឹងហាក់ដូចជាសកម្មភាពមនុស្សដ៏ស្និទ្ធណាម្នាក់ដែលធ្លាប់ធ្វើបែបនេះមកលើនាយញយដងហើយគ្រាន់តែនឹកមិនឃើញ។

«គេនោះមាននិយាយថាបងជាសង្សារចាស់ គួររៀបការជាមួយគេដែរអត់?»

ពិនណាប្ដូរពីពាក្យបងស្រីមកជា«គេ»។

ទោះនាងមិននិយាយកាចៗ តែLorenzoសម្គាល់ឃើញ ភាពខឹងសម្បានិងរើសអើងក្នុងទម្រង់នៃការនិយាយស្ដីរបស់គូដណ្ដឹងប្រឆាំងទៅនឹងបងស្រីខ្លួនច្បាស់ណាស់។

តើពិនណានិងសន្យាមួយណាទើបជាតួចិត្តអាក្រក់ពិតទៅ?

« ប្រាកដអត់? ថាអត់ស្គាល់ខ្ញុំ?»សម្ដីនាងលាន់មកវិញទៀតហើយក្នុងការចងចាំ។

យើងចាំសម្ដីគេគ្រប់ពាក្យ ហេតុអ្វីយើងបែរជាចាំមិនបាន ថាគេជាអ្នកណា?

ហេតុអ្វីយើងចោលម្សៀតម្ល៉េះ អាLorenzo?

«បងឈឺក្បាលណាស់!»

គេរអ៊ូជាលេស។

 គ្រប់យ៉ាងបង្ហាញថា អ្វីម្យ៉ាងកំពុងរារាំងនៅចំពាក់កណ្តាលនៃគម្រោងអាពាហ៍ពិពាហ៍នេះ ។មនុស្សប្រុសម្នាក់ ដែលមិនដឹងពីអតីតកាលរបស់ខ្លួន បែរជាកំពុងត្រៀមរង់ចាំរៀបការជាមួយមនុស្សស្រីម្នាក់ ដែលខ្លួនមិនមានអារម្មណ៍អ្វីជាមួយសោះ ខណៈដែលមនុស្សស្រីរោគចិត្តម្នាក់ទៀត កំពុងខាបយកបេះដូងនាយសូម្បីត្រឹមជួបគ្នាដំបូង១៥នាទីគត់។

ពិនណាគ្មានជម្រើសអ្វីក្រៅពីធ្វើតាមចិត្តគេក្នុងការCancelចោលការញ៉ាំអាហាររ៉ូមែនទិក។

នៅលើឡានដែលគេកំពុងជូននាងមកផ្ទះ ពិនណាចាប់ផ្តើមឆ្លៀតឱកាសនិយាយចាក់ដោតះ

«Lorenអ្ហ៎ា បងស្រីអូនពូកែល្បិចណាស់ !អញ្ចឹងហើយបានជាអូនមិនចង់ឱ្យបងជួបគាត់! ក្រោយៗបើគាត់ទៅទៀត Lorenបដិសេធគាត់ក៏បាន ពិនណាមិនខឹងទេ!»

ប្រុសស្អាតដែលមានសេសសល់ស្នាមរបួសដោយអន្លើមួយចំហៀងមុខមើលខ្លួនឯងក្នុងកញ្ចក់ឡាន ។ គេមិននិយាយអ្វីច្រើន តែគេគិតច្រើនមហាច្រើន។

មនុស្សអាក្រក់ហើយពិការខួរក្បាលដូចយើង បើមានគេមកទទួលស្គាល់ជាសង្សារមានតែរោគចិត្តពិតមែនហើយ។

«បងឈឺអី?ហេតុអី?»

សំឡេងនាងកាលពីម្សិល។នេះឬសម្តីមនុស្សរោគចិត្ត?

គេនឹកដល់ត្រង់ណេះ ឡានក៏ឈប់ង៉ក់ក្នុងរបងផ្ទះនាយកគ្រឹះស្ថានហិរញ្ញវត្ថុដ៏ធំសម្បើម ។ ក្រោយបើកទ្វារជូនគូដណ្តឹងចុះដោយមិនមានលាគ្នាមួយម៉ាត់ គេថយចូលមកក្នុងឡានវិញហើយមុនពេលរឺយែចេញ  គេចង់ធ្វើការងារមួយណាស់ គឺ.....ងើយមុខសម្លឹងបង្អួចផ្ទះនេះ តើបន្ទប់ណាមួយទៅដែលស្រីរោគចិត្តកំពុងរស់នៅ?

គេមិនដឹងទេ ព្រោះកន្លងមកគេមិនដែលចង់ដឹងអ្វីឡើយទាក់ទងនឹងវីរីណា ។

ប៉ុន្មានម៉ោងប៉ុណ្ណោះ គ្រប់យ៉ាងបានផ្លាស់ប្តូរ។ គេស្រាប់តែចង់ដឹងណាស់គ្រប់យ៉ាងតែម្តងដែលទាក់ទងនឹងនាង។

រំពេចនោះ ស្រមោលអ្នកណាម្នាក់នៅជាន់ខាងលើ។

ជាមនុស្សស្រី។

Lorenzo រវេភ្នែកត្របាញ់ទៅកាន់ទីនោះ។

គឺនាងមែនហើយ! រាងរៅរបស់នាង ដំណើរនាង កាយវិការនាងជួបតែម្តងក៏ស្គាល់ច្បាស់។ សម្លឹងឆ្ងាយប៉ុណ្ណានៅតែឃើញច្បាស់និងមានអារម្មណ៍ដឹងថា ជានាង។

ស្នាមបបូរមាត់នាង និងរង្វង់ដៃដែលលោមកចង់ឱបកនាយ បានធ្វើឱ្យបេះដូងអ្នករបួសចាប់រំភើបហើយលោតញាប់។

យើងចង់ថើបនាងម្តងទៀត?

សំណួរដែលសួរខ្លួនឯងព្រមមកជាមួយចម្លើយឧត្តមគតិថា «ទេ!»នាងជាបងស្រីអនាគតភរិយាយើងជាមនុស្សឬសត្វដែលធ្វើបែបនេះ?

ចុះ ដែលនាងនៅខាងលើ នាងមាននឹកយើងដូចដែលយើងកំពុងមានចិត្តដែរទេ? នាងមកមើលយើងតាំងពីអង្កាល់? ឬមួយក៏ នាងតែងតែធ្វើដូច្នេះ គឺលួចមើលយើងពីជាន់ខាងលើមក ប៉ុន្តែយើងមិនដែលចាប់អារម្មណ៍?

គេដកខ្សែភ្នែកមកវិញហើយរំយែទ្បានថយពីរបងភូមិគ្រឹះ។ សម្តីពិនណាលាន់មកវិញក្នុងការចងចាំ«ប្រាប់ហើយថាគាត់ទើបរើមកផ្ទះវិញបន្ទាប់ពីទៅនៅខាត់ព្រាត់ក្រៅអស់ម្ភៃឆ្នាំ!មកវិញគាត់ខឹងប៉ាហើយខឹងខ្ញុំ គាត់ចង់ដណ្តើមសូម្បីភាគហ៊ុនធំនៅOCហើយនិង ចុងក្រោយ ឃើញបងLorenគាត់ក៏......»

សម្តីពិនណា ដែលតែងតែលើកឡើងថា បងស្រីរបស់នាងម្នាក់នេះ កំពុងចង់ដណ្តើមយើងចេញពីរង្វង់អាពាហ៍ពិពាហ៍របស់ប្អូនស្រីគេ តើពិតកម្រិតណា? នាងគិតយ៉ាងណាដែលចង់ធ្វើអ៊ីចឹង?ហើយធ្វើដើម្បីអ្វីទៅវិរីណា?

សន្យាក៏ដោយវិរីណាក៏ដោយតើហេតុអ្វីក្រោយជួបគ្នាហើយយើងមានអារម្មណ៍ថាហាក់បីដូចជាបានធ្វើអ្វីមួយខុសៗចំពោះនាង?

ម្តេចក៏នៅសុខៗ លែងរស់នៅស្ងប់ហើយបែរជាមានអារម្មណ៍ថាជំពាក់ស្រីម្នាក់នេះ?

យើងកំពុងលង់អន្ទាក់ស្រីវិកលពេញដោយមហិច្ឆតាម្នាក់នោះ ?

គិតដល់ត្រង់ណេះ គេរវៃចង្កូតបញ្ឆោឡានចាកចេញ។ ចិត្តមួយអ្នកប្រុសចង់គេចវេះពីនាង ចិត្តមួយទៀតនៅទទូចចង់ដឹងការពិត។

គ្មានអ្នកណាបញ្ឆោបេះដូងបានទេ។ គេស្រាប់តែមានអារម្មណ៍ថាចង់សម្លឹងមើលនាងម្តងទៀតមុនពេលដាច់ចិត្តដកភ្នែកមកវិញហើយបោលឡានចាកចេញក្នុងលាន់ខ្ទរកណ្តាលរាត្រី។

Lorenzo រត់គេចពីសន្ទឹកបេះដូងខ្លួនឯងបានយូរប៉ុណ្ណាទៅ?

ប្រលោមលោកនេះមានជាសៀវភៅ តម្លៃ២៥០០០រៀល

ទំនាក់ទំនង ០១៥២១៣១១១ និង ០១៦២១៣១១១